# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ២២៦ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការប្រែក្លាយមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈអគ្គិសនីកម្ពុជា ទៅជាវិទ្យាស្ថានវិទ្យាសាស្ត្រអគ្គិសនី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ស្តីពីលក្ខណវិនិច្ឆ័យនៃកាបង្កើតសាកលវិទ្យាល័យ

យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

# សម្រេច

**មាត្រា ១.-**

ត្រូវប្រែក្លាយមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈអគ្គិសនីកម្ពុជា ទៅជាវិទ្យាស្ថានវិទ្យាសាស្ត្រអគ្គិសនី (Institute of Electrical Science) សរសេរកាត់ជាភាសាខ្មែរ **វ.វ.អ** និង សរសេរកាត់ជា ភាសាអង់គ្លេស I.E.S ដើម្បីបណ្តុះបណ្តាលធនធានមនុស្សលើវិស័យអគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ២.-**

**វ.វ.អ** ស្ថិតនៅក្រោមការគ្រប់គ្រងរបស់អគ្គិសនីកម្ពុជា និងស្ថិតនៅក្រោមអាណាព្យាបាលរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។

**វ.វ.អ** មានទីតាំងស្ថិតនៅផ្លូវចម្ការដូង ភូមិសំបួរ សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ។

**មាត្រា ៣.-**

**វ.វ.អ** ដឹកនាំដោយនាយក ០១រូប អមដោយនាយករង មួយចំនួនជាជំនួយការតាមការចាំបាច់។ ការរៀបចំតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធគ្រប់គ្រងរបស់ **វ.វ.អ** ត្រូវគោរពតាមលក្ខន្តិកៈរបស់អគ្គិសនីកម្ពុជា និងមានការឯកភាពពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**មាត្រា ៤.-**

**វ.វ.អ** ធ្វើការបណ្តុះបណ្តាលកម្រិតបរិញ្ញាបត្ររង និង បរិញ្ញាបត្រលើឯកទេសអគ្គិសនី។ **វ.វ.អ** អាចធ្វើការបណ្តុះបណ្តាលវគ្គខ្លីលើជំនាញបច្ចេកទេសអគ្គិសនី។

**មាត្រា ៥.-**

**វ.វ.អ** ត្រូវរៀបចំកម្មវិធីសិក្សាលម្អិតគ្រប់កម្រិត ស្របតាមគោលការណ៍កំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា ៦.-**

លក្ខខណ្ឌនៃការជ្រើសរើសនិស្សិតឲ្យចូលរៀននៅ **វ.វ.អ** ត្រូវគោរពទៅតាមបទដ្ឋានស្តីពីការកំណត់លក្ខខណ្ឌនៃការចូលរៀននៅឧត្តមសិក្សា។

**មាត្រា ៧.-**

និស្សិតដែលបានរៀនចប់តាមកម្មវិធីសិក្សារបស់ **វ.វ.អ** និងទទួលបានជោគជ័យក្នុងការប្រឡងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាបត្រតាមកម្រិត និងឯកទេសដែលបានសិក្សា។ សញ្ញាបត្រនេះត្រូវផ្តល់ឲ្យដោយ **វ.វ.អ** ហើយត្រូវទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា ៨.-**

**វ.វ.អ** មានប្រភពធនធានដូចខាងក្រោម៖

- ថវិកាជាតិដែលជាឧបសម្ព័ន្ធក្នុងកញ្ចប់ថវិការបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

ថវិកាដែលស្ថិតក្នុងកញ្ចប់មូលនិធិរបស់អគ្គិសនីកម្ពុជា
- ការបង់ថ្លៃបណ្តុះបណ្តាល
- ហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍នានា ការបរិច្ចាករបស់សប្បុរសជន និងជំនួយឥតសំណង ឬកម្ចីដែលធ្វើឡើងតាមការយល់ព្រមពីអគ្គិសនីកម្ពុជា ។

**ខ.ខ.អ.** មានសិទ្ធិទទួល និងគ្រប់គ្រងមូលនិធិជំនួយផ្នែកបច្ចេកទេស និងសម្ភារៈផ្សេងៗទៀត ពីប្រភពក្នុង ឬក្រៅប្រទេសសម្រាប់បម្រើសេចក្តីត្រូវការក្នុងការបំពេញមុខងារ និងភារកិច្ចរបស់ខ្លួន។

## មាត្រា ៩.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍។

## មាត្រា ១០.-

រដ្ឋមន្ត្រីទទួលបន្ទុកស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកអគ្គិសនីកម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែតុលា ឆ្នាំ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១០
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ